Seattle Public Utilities

King County

Be RainWise

Manage your rain water at home

# សួនច្បារស្រូបទឹកភ្លៀង និងធុងស្តុកទឹកភ្លៀង

## ការណែនាំអំពីការថែទាំ

សូមអរគុណអ្នកសម្រាប់ការថែទាំសួនច្បារស្រូបទឹកភ្លៀង និងធុងស្តុកទឹកភ្លៀងរបស់អ្នក ដើម្បីការពារផ្លូវទឹករបស់យើង ។






*ទីក្រុងស៊ីអាថល និង ខោនធី King ចាប់ដៃគូជាមួយគ្នា ធ្វើគម្រោង RainWise ដោយផ្តល់ជូននូវទឹកប្រាក់សំណងសម្រាប់ធ្វើធុងស្តុកទឹកភ្លៀង និងសួនច្បារស្រូបទឹកភ្លៀង នៅលើដីជាឯកជនរបស់អ្នក ។*

*ស្វែងយល់បន្ថែមតាមវិបសាយ www.rainwise.seattle.gov .*

# សួនច្បារស្រូបទឹកភ្លៀង

## ស្មៅឥតប្រយោជន៍:

ស្មៅឥតប្រយោជន៍អាចប៉ះពាល់ដល់រុក្ខជាតិតូចៗ  ហើយដុះរាលដាលយ៉ាងឆាប់រហ័ស ។ ចូរដកស្មៅឥតប្រយោជន៍ទាំងនោះដោយដៃ ឬប្រើជំនីកដកស្មៅឥតប្រយោជន៍នោះចេញ ។ ដកស្មៅឥតប្រយោជន៍នោះចេញពេញមួយឆ្នាំ ជាពិសេសនៅចុងរដូវធ្លាក់ទឹកកក រដូវផ្ការីក និងដើមរដូវស្លឹកឈើជ្រុះ នៅពេលដែលដីនៅតែមានសំណើមនៅឡើយ ។ **ដកស្មៅឱ្យអស់ - ទាញទាំងឫសឱ្យអស់ -** ដូច្នេះវាមិនដុះឡើងវិញភ្លាមបានទេ ។ **ចូរកុំប្រើថ្នាំសំលាប់ស្មៅ ,ថ្នាំសំលាប់សត្វល្អិត** នៅក្នុងសួនច្បារស្រូបទឹកភ្លៀងរបស់អ្នកឱ្យសោះ ។



**ស្មៅឥតប្រយោជន៍:** ដកស្មៅឥតប្រយោជន៍ទាំងអស់ចេញ ចូរដកទាំងឫស ។

## កំទិចឈើ:

កំទិចឈើ (ដូចជាជីកំប៉ុស ស្លឹកឈើ និងកំទិចឈើកិន) ការពារកុំឱ្យដុះស្មៅឥតប្រយោជន៍ អភិរក្សទឹក និងការពារឫសឈើ ។ **ចូរពិនិត្យ និងមើលថែស្រទាប់កំទិចឈើនោះឱ្យមានកម្រាស់ ៣ អ៊ីញ** *ដែលជាការចាំបាច់* ។ កំទិចឈើដ៏ល្អបំផុតនៅក្នុងសួនច្បារស្រូបទឹកភ្លៀងគឺកំទិចឈើកិន ដែលអាចរកបានដោយឥតគិតថ្លៃពីសេវាកម្មផ្តល់ដើមឈើ ។ ចូររកមើលថាមានតំបន់ណាមួយដែលមានដី ហើយត្រូវដាក់កំទិចឈើគ្របដីនោះ នៅពេលដែលចាំបាច់ ។ ចូរប្រុងប្រយ័ត្នចៀសវាងយកកំទិចឈើទៅគ្របសង្កត់លើរុក្ខជាតិដែលអ្នកដាំ ។



**កំទិចឈើ:** ចូររាយកំទិចឈើដូចជាកំទិចឈើកិននៅលើដី ។

## ការស្រោចទឹក:

រុក្ខជាតិដែលនៅតូចត្រូវការទឹកដើម្បីដុះឫសឱ្យបានរឹងមាំ ។ **ការស្រោចទឹកគឺមានសារៈសំខាន់ក្នុងកំឡុងពេលរដូវក្តៅពីរទៅបីរដូវដំបូង** បន្ទាប់ពីបានតំឡើងសួនច្បារស្រូបទឹកភ្លៀងរបស់អ្នក ។ ជាទូទៅ ស្រោចទឹក ពេលអាកាសធាតុស្ងួត និងក្តៅ ចាប់ពីខែឧសភាដល់ខែកញ្ញា ។ ចូរស្រោចទឹកនៅមុនម៉ោង ៨ ព្រឹក គឺជាពេលល្អបំផុត ដើម្បីកាត់បន្ថយការហួត ។

*ចូរប្រាកដថាស្រោចទឹកឱ្យជោគ ឱ្យដីមានសំណើមពី ៦-១២ អ៊ិនចូលក្នុងដី* ។ បន្ទាប់ពីស្រោចទឹករួច ចូរចាំមួយម៉ោងរួចជីកដី ដើម្បីមើលថាតើទឹកនោះបានស្រោចជោគដែរឬអត់ ។

អ្នកអាចប្រើប្រដាប់ស្រោចទឹក ឬបើចង់ចំណេញពេល ចូរដាក់បំពង់បង្ហូរទឹកនៅជាប់ដើមឈើរបស់អ្នក ហើយគ្របបំពង់ទឹកនោះជាមួយកំទិចឈើ ។ សិក្សាបន្ថែមអំពីវិធីស្រោចទឹកចំពោះដើមឈើដាំថ្មី និងរបៀបប្រើទុយោចោះបង្ហូរទឹកនៅឯ **www.seattle.gov/util/environmentconservation/mylawngarden/smart_watering** ។

| អាយុកាលរបស់សួនច្បារ | ការស្រោចទឹក |
|---|---|
| ឆ្នាំទី ១ | រាល់ ៣-៤ ថ្ងៃម្តង |
| ឆ្នាំទី ២ | រៀងរាល់ ២ សប្តាហ៍ម្តង |
| ឆ្នាំទី ៣ | ស្រោចម្តងក្នុងមួយខែឬស្រោចច្រើនជាងនេះ អាស្រ័យថាតើស្លឹកនោះវាក្រៀមខ្សោះទឹកដែរឬអត់ (ខ្សោះទឹកហួស ក្រៀមឡើងពណ៌ត្នោត) |



**ការស្រោចទឹក:** ស្រោចទឹកឱ្យបានជោគ ។

## ការដាំដើមឈើ:

ប្រសិនបើអ្នកត្រូវការដកដើមឈើដែលងាប់ឬក្រៀមនោះចេញ  **ចូរដាំវាជំនួសនៅពេលរដូវស្លឹកឈើជ្រុះ។** អញ្ចឹងវានឹងផ្តល់ពេលវេលាឱ្យដើមឈើដុះលូតលាស់ឫសបានរឹងមាំ នៅមុនពេលរដូវប្រាំង ។ ការចាក់ឫសដុះរឹងមាំជួយដើមឈើឱ្យប្រយុទ្ធប្រឆាំងនឹងជំងឺ ទប់ទល់បាននៅរដូវក្តៅ និងរដូវធ្លាក់ទឹកកក ។



**ការដាំដើមឈើ:** រដូវស្លឹកឈើជ្រុះគឺជាពេលវេលាដ៏ល្អបំផុតដើម្បីដាំដើមឈើជំនួស ។

## ការសំអាត:

សំរាមនិងកំទេចកំទីអាចស្ទះច្រកទឹកហូរចេញចូលបាន ។ **លាងសម្អាតយកដីភក់ កំទិចកំទី ឬសំរាមចេញពីក្នុងសួនច្បារស្រូបទឹកភ្លៀងរបស់អ្នកឱ្យបានទៀងទាត់។** ចូរពិនិត្យមើលលំហូរទឹកនៅពេលដែលមានភ្លៀងចាប់ផ្តើមធ្លាក់នៅរដូវស្លឹកឈើជ្រុះ ហើយភ្លៀងម្តងទៀតក្នុងរដូវធ្លាក់ទឹកកក ។

# ស្មៅឥតប្រយោជន៍ដែលត្រូវតែដកចេញ

សូមមើលការណែនាំពេញលេញអំពីឈ្មោះស្មៅឥតប្រយោជន៍ជាទូទៅនៅឯ **www.portlandoregon.gov/bes/article/471991**



**ប្រភេទដើម Himalayan Blackberry**
ជាវល្លិ៍ដែលមានបន្លា និងចេញផ្លែពណ៌ខ្មៅនៅរដូវក្តៅ ។



**ស្មៅ Dandelion**
មានឫសវែង ហើយជ្រៅ ។



**ស្មៅ Bindweed (Morning glory)**
ចេញផ្កាពណ៌ស ចាប់ពីរដូវផ្ការីករហូតដល់រដូវក្តៅ ។



**ស្មៅ Buttercup**
ចេញផ្កាពណ៌លឿងភ្លឺចាំង ។
វាដុះរាលដាលយ៉ាងខ្លាំងនៅក្នុងតំបន់ដែលមានសំណើម ។



**ស្មៅ English Ivy**
ជាវល្លិ៍ដែលដុះលឿនជាទីបំផុត ។



**ស្មៅ Vetch**
ចេញគ្រាប់ពូជជាច្រើនក្នុងស្រោម ក្រោយពេលចេញផ្កា ។



**ស្មៅ Herb Robert (Stinky Bob)**
ជាស្មៅដែលមានក្លិន ហើយមានឫសវែងត គ្នា ។



**ស្មៅ Bittercress / Shotweed**
បើប៉ះវាតែបន្តិច គ្រាប់វាបែកឡើង ។



**ស្មៅធម្មជាតិ**
ស្មៅធម្មជាតិដែលដុះព័ទ្ធជុំវិញវាលស្មៅដាំ
អាចដុះរាលដាលចូលក្នុងសួនច្បាររបស់អ្នក
ហើយក្លាយជាស្មៅឥតប្រយោជន៍ ។

# ធុងស្តុកទឹកភ្លៀង

## យល់ដឹងពីធុងស្តុកទឹកភ្លៀងរបស់អ្នក:







a. ទរបង្ហូរទឹក
b. គំរបធុង
c. សំណាញ់ (ក្រោមគំរប)
d. បំពង់បង្ហូរទឹកចេញ
e. ក្បាលរ៉ូប៊ីណេ
f. សន្ទះវ៉ាល់បិទ-បើកទឹក
g. រន្ធបិតទឹក
h. សន្ទះបិទរន្ធ (សូមមើលរូបភាពខាងក្រោម)

## មុនពេលរដូវស្លឹកឈើជ្រុះ ភ្លៀងចាប់ផ្តើមធ្លាក់មក ...

មុនពេលរដូវភ្លៀងធ្លាក់នាពេលស្លឹកឈើជ្រុះ ចូរត្រៀមធុងស្តុកទឹកភ្លៀងរបស់អ្នក ដើម្បីអាចឱ្យទឹកហូរបានតាមធុងស្តុកទឹករបស់អ្នក ទៅសួនច្បារស្រូបទឹកភ្លៀង ឬទៅលូទឹក។ ក្រោយមកនៅរដូវផ្ការីក អ្នកអាចប្រើធុងស្តុកទឹកភ្លៀងរបស់អ្នក ដើម្បីត្រងទឹក និងទុកវាប្រើសំរាប់ស្រោចសួនច្បាររបស់អ្នក។

## ខែសីហា: លាងសម្អាតធុងស្តុកទឹកភ្លៀងរបស់អ្នកឱ្យបានស្អាត

នៅពេលដែលធុងស្តុកទឹកភ្លៀងរបស់អ្នកជិតអស់ទឹក ចូរពិនិត្យមើលខាងក្នុងធុង ថាតើអ្នកត្រូវលាងសំអាតកំទិចដីនៅបាតធុង ឬស្លែកាន់ក្នុងធុងដែរឬទេ។

១. បើកក្បាលរ៉ូប៊ីណេនៅបាតធុង **(d)** ដើម្បីឱ្យទឹក និងកំទិចដីហូរចេញឱ្យអស់។

២. រំកិលទរបង្ហូរទឹក **(a)** ចេញពីគំរបធុង **(b)** ។

៣. បើកគំរបធុង **(b)** និងសំណាញ់ចេញ **(c)** ដើម្បីឱ្យអ្នកអាចលាងខាងក្នុងធុងបាន។

៤. បាញ់ទឹកចូលក្នុងធុងស្តុកទឹកដើម្បីសំអាតកំទិចកំទីចេញឱ្យអស់។

៥. មួលបិទរ៉ូប៊ីណេបាតធុង ដាក់សំណាញ់ និងបិទគំរប ដើម្បីឱ្យធុងស្តុកទឹកភ្លៀងរួចរាល់ ប្រើសម្រាប់រដូវវស្សា។

## ពីខែសីហា កញ្ញា: ជម្រះការស្ទះណាមួយ




១. បិទវ៉ាល់ **(f)** ដើម្បីស្តុកទឹកភ្លៀងវិញ។

២. ដោះរន្ធបង្ហូរទឹកដែលធ្វើពីប្លាស្ទិកពណ៌ស **(g)** ។

៣. យកសន្ទះបិទរន្ធនេះចេញ **(h)** - លាងវាររាំងចន្លោះរន្ធបង្ហូរទឹកប្លាស្ទិចនោះ។

៤. លាងសម្អាតរន្ធ និងត្រូវបាកដថាអ្នកអាចមើលឃើញតាមប្រហោង (នេះមានន័យថាទឹកអាចហូរចេញហើយ) ។

៥. បិទរន្ធនោះវិញ ភ្ជាប់បំពង់ឡើងវិញ ហើយបើកវ៉ាល់ដើម្បីឱ្យទឹកហូរម្តងទៀត។

## ខែកញ្ញា៖ បើកសន្ទះវ៉ាល់

សូមឱ្យទឹកក្នុងធុងហូរយឺតៗ ចូលទៅក្នុងសួនច្បារ ឬលូទឹករបស់អ្នក ដោយបើកសន្ទះវ៉ាល់ **(f)** ទៅរន្ធហូរតិចៗ។




(មូលបើកវ៉ាល់ឱ្យស្របជាមួយបំពង់។)

## ពីខែកញ្ញា - ឧសភា៖ លាងសំអាតទរទឹករបស់អ្នក និងពិនិត្យធុងស្តុកទឹកភ្លៀងរបស់អ្នក

ស្លឹកឈើដែលជ្រុះលើដំបូលរបស់អ្នកនឹងធ្លាក់ចូលក្នុងទរទឹករបស់អ្នក ហើយជាប់នឹងសំណាញ់ក្នុងធុងស្តុកទឹកភ្លៀងរបស់អ្នក។ ត្រូវចងចាំពិនិត្យមើលទរទឹក និងធុងស្តុកទឹកភ្លៀងរបស់អ្នកយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។

១. បង្វែរទរបង្ហូរទឹក **(a)** ឱ្យចេញពីរន្ធនៅក្នុងគំរបធុង **(b)** ។

២. ដោះ ហើយយកគំរបធុងស្តុកទឹកភ្លៀងចេញ ដើម្បីឱ្យអ្នកអាចមើលឃើញសំណាញ់ **(c)** ដែលនៅខាងក្រោម។

៣. យកស្លឹកឈើ ឬកំទេចកំទីផ្សេងៗចេញឱ្យអស់ពីសំណាញ់។

៤. គៀស ឬបាញ់ទឹកលាងសំរាមចេញ បន្ទាប់មកដាក់សំណាញ់ចូលក្នុងធុងស្តុកទឹកភ្លៀងវិញ។

៥. ដាក់គំរប មួសខ្មៅ និងដាក់ទរបង្ហូរទឹកឱ្យចូលកន្លែងដើមវិញ។




ជំហានទី ១-២




ជំហានទី ៣




ជំហានទី ៤

# ពេលចូលរដូវប្រាំង ...

## ខែឧសភា៖ បិទសន្ទះវ៉ាល់

បិទសន្ទះវ៉ាល់ **(f)** ដើម្បីបិទរន្ធកុំឱ្យហូរចេញនៅខែឧសភា ដើម្បីរក្សាទឹកទុកសម្រាប់ប្រើនៅរដូវប្រាំង។




## ពីខែឧសភា - សីហា៖ ប្រើទឹកភ្លៀងដែលស្តុកទុកក្នុងធុង

តភ្ជាប់ទុយោទឹកនឹងប្រដាប់ស្រោចទឹក **(e)** ដើម្បីប្រើទឹក ដែលអ្នកបានរក្សាទុកនៅក្នុងធុងស្តុកទឹកភ្លៀងរបស់អ្នក។



# ទរទឹកភ្លៀង

### សូមសំអាតទរទឹកភ្លៀងរបស់អ្នកឱ្យបានស្អាតល្អពេញមួយឆ្នាំ។

ស្លឹកឈើ សំរាម និង ធូលីជាច្រើន ជាប់លើដំបូលរបស់អ្នកពេញមួយឆ្នាំ ។ ប្រសិនបើដំបូលរបស់អ្នកជាដំបូលដែលមានសារធាតុគ្រើម (Composite) នោះសារធាតុគ្រើមដែលនៅលើដំបូលនោះ ប្រហែលជាអាចសឹកបន្តិចម្តងៗ ហើយធ្លាក់ចូលក្នុងទរទឹករបស់អ្នក ។ នៅទីបំផុត សំរាមទាំងនោះហូរចូលក្នុងទរទឹកភ្លៀងរបស់អ្នក រហូតទាល់តែភ្លៀងធ្លាក់លាងវាចេញពីទរ ហូរចូលទៅទរបង្ហូរទឹកចុះក្រោម ។ ដោយមិនបានចាប់អារម្មណ៏ ធុងស្តុកទឹកភ្លៀងរបស់អ្នកប្រហែលជាអាចស្ទះបាន ។



សូមលាងសម្អាតទរទឹករបស់អ្នកយ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ ដើម្បីរក្សាលំហូរទឹកភ្លៀង ។

# មានសំណួរ?

- តើត្រូវការឱ្យជួយកំណត់ថាតើរុក្ខជាតិនៅក្នុងសួនច្បាររបស់អ្នកគឺជាស្មៅឥតប្រយោជន៍ដែរឬទេ?
- មិនប្រាកដថា ត្រូវទៅទិញកំទិចឈើសម្រាប់ដាក់ក្រាលក្នុងសួនច្បារពីកន្លែងណា?
- ឆ្ងល់ថាតើត្រូវស្រោចទឹកសួនច្បាររបស់អ្នកញឹកញាប់ ឬច្រើនប៉ុណ្ណាដែរ?

សូមទំនាក់ទំនងមកកាន់ផ្នែកបំរើបណ្តាញសួនច្បារ តាមទូរស័ព្ទលេខ:
206-633-0224 ឬ **help@gardenhotline.org**
*មានផ្តល់ជូននូវសេវាបកប្រែច្រើនភាសា ។*

**ចូរថែទាំប្រព័ន្ធតំឡើងរបស់អ្នកយ៉ាងហោចណាស់ឱ្យបាន 5 ឆ្នាំ**

ក្រសួងសាធារណៈការប្រចាំទីក្រុងស៊ីអាថល (Seattle Public Utilities) និង ខោនទី គិនង គឺកំពុងពឹងផ្អែកលើគម្រោងប្រើទឹកភ្លៀង “RainWise” របស់អ្នក ដើម្បីគ្រប់គ្រងទឹកព្យុះភ្លៀងដែលមានជាតិពុល ។ សួនច្បារស្រូបទឹកភ្លៀង និង/ឬធុងស្តុកទឹកភ្លៀងរបស់អ្នក អាចធ្វើទៅបាន ដោយប្រើប្រាស់មូលនិធិសាធារណៈ ។ ហើយជាការឆ្លើយតប ការបន្តថែទាំរបស់អ្នកនឹងជួយការពារតំបន់ Puget Sound, បឹងវ៉ាស៊ីនតោន និងព្រែកនានាតាមទីក្រុងរបស់យើង ។

**ចូរប្រាប់ឱ្យយើងដឹងបើអ្នកដាក់លក់ផ្ទះរបស់អ្នក**

សូមចងចាំថាត្រូវទាក់ទងទៅក្រសួងសាធារណៈការប្រចាំទីក្រុងស៊ីអាថល ឬ ខោនធី King តាមលេខ 206-684-0100 ឬ **rainwise@seattle.gov** បើអ្នកមានបំណងចង់លក់ផ្ទះរបស់អ្នក ។ ការតម្លើង RainWise របស់អ្នកត្រូវតែចុះសរសេរនៅក្នុងបែបបទបញ្ចេញពតិមានអំពីម្ចាស់ផ្ទះរបស់អ្នក ដើម្បីឱ្យម្ចាស់ផ្ទះថ្មីបានដឹងអំពីធុងស្តុកទឹកនិង/ឬសួនច្បារស្រូបទឹកភ្លៀងរបស់អ្នក ។

**សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅមើលនៅ:** **www.rainwise.seattle.gov**